# សួនកំណាព្យកុមារ



មជ្ឈមណ្ឌលពុទ្ធិកការសៀវភៅ អ៊ីជាង

**គណៈកម្មការនាយក**

លោក សុក ប៊ុន ហេង

លោក សោម ឆេង

លោក តូ ហូ

**អ្នកនិពន្ធ**

អ្នកស្រី ឆេង សុភ័ព្វ



**គណៈកម្មការវិចិត្រករ**

លោក អ៊ិន យី

លោក តឹង គិម និត

លោក ឈុំ សំជិត

លោក ដួង កាយ

លោក ស្បោង ផាន់

លោក ប៉ា ស្រ៊ុន

លោក សំរិទ្ធ សុខុម

លោក ឆាន់ សំបូរ

**គណៈកម្មការពិនិត្យ**

លោក ឡុង ឈុំម

លោក ហៃ លី

អ្នកស្រី ពឹង គិម សួរ

អ្នកស្រី ធូ ថេន

លោក គង់ ហ៊ល

លោក ចក់ អ៊ិត

# ករថាមុខ

សួនកំណាព្យកុមារជាកំណាព្យអប់រំកុមារតូចៗ អោយមានបទបែបល្អក្នុងការរស់នៅ។ សៀវភៅនេះយើងបានបោះពុម្ពលើកទី១ មុនឆ្នាំ១៩៧៥ ហើយបានយកទៅបង្រៀននៅមត្តេយ្យសាលានានាក្នុងទីក្រុងភ្នំពេញ។ បោះពុម្ពលើកនេះ យើងបានរៀបចំជាថ្មីឡើងវិញ ផ្នែករូបភាពនិងទំព័រ អោយកាន់តែល្អឡើងទៀត តែយើងបានរក្សាទុកនូវពាក្យកាព្យទាំងស្រុងឥតកែប្រែ។

យើងសង្ឃឹមថា សួនកំណាព្យកុមារប្រាកដជាបំរើអារម្មណ៍កុមារតូចៗរបស់យើងអោយទៅកាន់កិរិយាសុភាពរាបសា ថ្លៃថ្នូរ និងមានអនាម័យល្អប្រសើរពុំខាន។

**អ្នកនិពន្ធ**

អ្នកស្រី ឆេង សុភ័ព្វ



# ខ្ញុំធ្វើអ្វីខ្លះ

(បទកាកគតិ)

ម៉ោងប្រាំកន្លះ ក្រោកយ៉ាងរហ័ស
ហាត់ប្រាណលុបមុខ សូត្រសមមេរៀន
ដែលទន្ទេញទុក ពីល្ងាចគ្រប់មុខ
ប្រសើរណាស់ណា។



ប្រាំមួយកន្លះ ស្លៀកពាក់រួតរះ
ស្រស់ស្រូបអាហារ មុននឹងទៅរៀន
លាម៉ាក់លាប៉ា លោកតែងផ្តាំថា
អោយខ្ញុំខំរៀន។





## ខ្ញុំធ្វើអ្វីខ្លះ (បទកាកគតិ)

ថ្ងៃម៉ោងដប់ពីរ ដប់ប្រាំនាទី
ក្រោយបាយម៉ាក់មាន ប្រសាសន៍អោយគេង
មួយម៉ោងទើបបាន សុខភាពដល់ប្រាណ
រៀនសូត្រពូកែ។

ក្រោកពីគេងថ្ងៃ ររៀសរវ៉ៃ
ងូតទឹកដុសថៃ ខ្លួនប្រាណអោយស្អាត
ជើងដៃផងដែរ កខ្វក់មុខតែ
ត្រូវទណ្ឌកម្ម។

ម៉ោងដប់ប្រាំបួន ទន្ទេញច្បាប់ក្បួន
មេរៀនអោយចាំ កិច្ចការសាលា
អ្នកគ្រូបានផ្ដាំ ធ្វើអោយមុតមាំ
ទើបហៅសិស្សល្អ។





# ក្រោកពីព្រឹក

(បទកាកគតិ)

គេងក្រោកពីព្រឹក ហាត់ប្រាណងូតទឹក
អោយបានមុនគេ ស្លូត្រសាកមេរៀន
កុំនៅទំនេរ រួចហើយរិះរេ
រៀបចំទៅរៀន។

ធ្វើបានដូច្នេះ កុមារនឹងចេះ
ប្រាជ្ញាក៏មាន ម៉ាក់ប៉ាស្រឡាញ់
លោកគ្រូរាប់អាន មិត្តទាំងប៉ុន្មាន
មិនហ៊ានមើលងាយ។

# កូនមានពូជ

(បទកាកគតិ)

រៀបទៅសាលា ជំរាបលាប៉ា
អ្នកម៉ាក់ផងដែរ លើកដៃសំពះ
តាមរបៀបខ្មែរ ព្រោះលោកបានថៃ
ថ្នាក់ថ្នមរូបពៅ។

ពេលវិលមកផ្ទះ លើកដៃសំពះ
ដូចកាលពេលទៅ ជំរាបសួរប៉ា
សួរម៉ាក់ទើបត្រូវ ទើបបានលោកហៅ
ថាកូនមានពូជ។



# ថាអរគុណ

(បទកាកគតិ)



ពេលម៉ាក់ហុចនំ មុនយកនោះខ្ញុំ
ថាអរគុណម៉ាក់ លើកដៃសំពះ
លោកញញឹមដាក់ រួចលោកបញ្ឆាក់
ថាខ្ញុំចេះណាស់។

ខ្ញុំសប្បាយចិត្ត ចាំពាក្យនេះពិត
មិនភ្លេចផ្ដេសផ្ដាស មុនទទួលអ្វី
ថាយ៉ាងរហ័ស អរគុណយ៉ាងច្បាស់
ទើបចាស់ពេញចិត្ត។

# លាងដៃ

(បទកាកគតិ)

មុនញ៉ាំលាងដៃ    ក្រោយញ៉ាំលាងដៃ
កុំនៅដំអក់    លាងក្រោយពេលលេង
លាងពេលកខ្វក់    ដៃណាអាក្រក់
កើតកមរមាស់។

ដៃមានមេរោគ    ដៃណាស្មោកគ្រោក
ឥតថែទាំសោះ    ចាប់កាន់ចំណី
ញ៉ាំចូលក្នុងពោះ    មេរោគទាំងនោះ
ចូលតាមទៅដែរ។





# ដង្កូវស៊ីធ្មេញ

(បទកាកគតិ)

ធ្មេញស្អាតដង្កូវ ឥតចិត្តចង់នៅ

ព្រោះឥតអីធី ធ្មេញជាប់កំទេច

អាហារចំណី ធ្មេញស្អុយឥតបី

ដង្កូវចូលចិត្ត។

ចង់ដេញដង្កូវ កុំអោយចូលទៅ

ស៊ីធ្មេញបានពិត យើងត្រូវដុសធ្មេញ

ព្រឹកល្ងាចកុំរិត តែខ្ជិលប្រព្រឹត្ត

ធ្មេញពិតជាខូច។

# លុបមុខ

(បទកាកគតិ)

មុខសមមង់រុយ ហិចហើររពុយ
ក្រឡឹងភក្ត្រា ខ្លះទំប្រមុះ
ចុះលើចង្កា រំខាននេត្រា
មុខណាកខ្វក់។

បើចង់ចៀសវាង យើងត្រូវលុបលាង
មុខកុំដំអក់ លាងព្រឹកលាងល្ងាច
លាងរួចសិតសក់ បាត់ធុំអាក្រក់
ទើបរុយមិនរោម។





# រឿងទំនួញបាយមួយគ្រាប់

(បទព្រហ្មគីតិ)

ថ្លែងពីបាយមួយគ្រាប់ ជ្រុះទៅជាប់លើកៅអី
រមៀលធ្លាក់មកដី ជិតដល់ក្តីមរណា។
ស្រែកយំថ្លែងរៀបរាប់ ថា៖ “យើងធ្លាប់មានមេត្តា
ដល់មនុស្សគ្រប់រូបា អោយភោក្តារស់ជីវិត។
កើតចេញពីពោះម៉ែ បានអ្នកស្រែបោកបែនពិត
កិនបុកយ៉ាងប្រណីត អស់ពីចិត្តទើបដណ្តាំ។





## រឿងទំនួញបាយមួយគ្រាប់ (ត)

ឆ្អិនបានខ្ញុំជាបាយ　　មនុស្សទាំងឡាយប្រញាយញាំ
បានឆ្អែតគួរចងចាំ　　ពាក្យបណ្តាំថាបាយថ្លៃ។
បណ្តោយអោយកំពប់　　ខ្ចាតទៅគ្រប់ទិសទីនៃ
ខ្ញុំនិងមិត្តផងភ័យ　　ឈឺចាប់ក្រៃសោកសង្រេង។
មិនគួរគេបំភ្លេច　　ខ្ញុំភាគតិចអោយសូន្យផេង
ឱះ ឱ! កម្មពីព្រេង　　គេវង្វេងឥតអាសូរ»។



# សំអាតខ្លួន

(បទកាកគតិ)

ងូតទឹកដុសខ្លួន កុំគេចវេះពួន
ខ្លាចទឹកមិនជា ងូតដុសសាប៊ូ
អោយស្អាតរាល់គ្រា ទើបរោគនានា
មិនអាចកើតបាន។
ខ្លួនមានញើសក្អែល ក្លិនស្អុយមិនដែល
អ្នកផងរាប់អាន គេខ្ពើមរអើម
មិនអោយប៉ះប្រាណ ក្មេងទាំងប៉ុន្មាន
មិនអោយលេងចូល។



# សំអាតសក់

(បទកាកគតិ)

សក់ណាកន្រ្ទើង សក់ណាសើងមើង
ឥតល្អមើលសោះ ចៃនៅត្រសុក
ពងញ៉ុកទាំងអស់ ស៊ីជុះគ្មានលស់
ព្រោះក្បាលគគ្រិច។

ចង់កំចាត់ចៃ កក់សិតរាល់ថ្ងៃ
អោយស្អាតជានិច្ច ចៃនឹងវិនាស
បាត់មួយរំពេច ច្នេះគួរកុំគេច
កុំភ្លេចកក់សក់។



# ញើសសំបោរ

(បទកាកគតិ)

កុំស្រូបសំបោរ　　កុំជូតជើងខោ
កុំប៉ាតខ្នងដៃ　　កុំជូតនឹងអាវ
អាក្រក់ពេកក្រៃ　　ខុសអនាម័យ
នឹងអ្នកជិតខាង។

ញើសដាក់កន្សែង　　ទុកមួយកន្លែង
រួចហើយដុសលាង　　ទឹកនិងសាប៊ូ
កុំយូរណានាង　　ស្អាតទើបវៃវាង
រៀនសូត្រឆាប់ចេះ។







# ថែសំលៀកបំពាក់

(បទកាកគតិ)

អាវថ្មីខោថ្មី សក់កាត់យ៉ាងខ្លី
ស្បែកជើងហ៊ីហា ចូលរៀនដំបូង
យើងស្អាតអស្ចារ្យ អ្នកម៉ាក់លោកប៉ា
ផ្តាំថាអោយថែ។

កុំអោយប្រឡាក់ ទឹកខ្មៅខ្ទាតដាក់
ដីសផងដែរ កុំប៉ប៉ុកដី
វាយគ្នាគ្មានល្ហែ លោតហក់មុខតែ
ដាច់ដាចមិនខាន។



# រឿងខ្ជិលសំអាត

(បទបន្ទោលកាក)

ថ្ងៃនេះកុមារ　　លេងភ្លេចអាត្មាតែម្តង
សប្បាយកន្លង　　ឥតគិតរឿងសំអាតសោះ។
ដេកទាំងគ្រិច　　លក់មួយរំពេចពេលនោះ
ជើងដៃហៅឈ្មោះ　　ថា៖ "នែ!កុមារអប្រិយ។
ម្តេចមិនសំអាត　　ខ្លួនយើងអោយស្អាតសោះវុី
ខ្លួនប្រាណអីៗ　　សក់ភ្នែកត្រចៀកនិងមុខ។
អោយយើងស្រមក　　អញចង់តែត្បកមិនទុក
ក្មេងខ្ជិលគគ្រុក　　ចង់តែស្រណុកពេកហោង។

# រឿងក្មេងសំអាត (ត)

លាងយើងអោយធាប់ តិចថាមិនប្រាប់មុនផង
យើងមានបំណង ជៀសវាងអោយផុតមេរោគ»។
ឮច្បាស់កុមារ ខំស្ទុះឆ្លេឆ្លាទាំងសោក
ភ័យបែកញើសជោក ប្រវេប្រវាងូតទឹក។
លាងមុខត្រចៀក ភ្នែកសក់និងក្លៀកសន្ទឹក
ដៃជើងរួចនឹក ថាថ្ងៃយប់ព្រឹកលែងភ្លេច។



# សណ្ដាប់ធ្នាប់ក្នុងពេលញាំ

(បទកាកគតិ)

ពេលញុំាអាហារ សម្រួលកាយា
អោយបានសមរម្យ ញុំាដោយស្ងៀមស្ងាត់
មួយៗរមទម លូកម្ហូបលូកនំ
នឹងសមស្លាបព្រា។

កព័ទ្ធកន្សែង ដៃកុំចំខែង
ប៉ះគេគ្រប់គ្នា ហុតទឹកសម្ល
ឬក៏ទំពា អាហារនានា
កុំអោយឮសូរ។





# ត្រូវចេះញាំ

(បទកាកគតិ)

កុំយកស្លាបព្រា ជ្រាវម្ហូបនានា
អោយរល់រក់អស់ កុំលូកចំណី
នឹងដៃអោយសោះ ព្រោះធ្វើដូច្នោះ
ខុសពេកកន្លង។

លើកកែវទឹកញាំ មាត់ពេញរង់ចាំ
លេបអស់សិនហោង ផឹកទាំងបង្ហំ
បាយផងទឹកផង ផឹកមិនទំនង
គ្មានអនាម័យ។